# ព្រះរាជក្រម

នស/រកម/០១០៦/០០២

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញា ស្តីពីការត្រួតពិនិត្យថ្នាំជក់

**មាត្រា ១.–**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញា ស្តីពីការត្រួតពិនិត្យថ្នាំជក់ ដែលធ្វើនៅទីក្រុងហ្សឺណែវ នាថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៣ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.–**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០០៦

នស/រកម.០១០៦.០២០ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**
**ហត្ថលេខា**
**នុត សុខុម**

លេខៈ ៣៧ . ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែមករា ឆ្នាំ២០០៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ឈាឌី តាន់**

អង្គការសុខភាពពិភពលោក
ទីក្រុងហ្សឺណែវ ប្រទេសស្វីស

# អនុសញ្ញារបស់អង្គការសុខភាពពិភពលោក
# ស្តីពី
# ការត្រួតពិនិត្យថ្នាំជក់

អង្គការសុខភាពពិភពលោក
ឆ្នាំ២០០៣

ទិន្នន័យនៃឯកសារផ្សព្វផ្សាយបញ្ចូលក្នុងបញ្ជីរបស់បណ្ណាល័យនៃអង្គការសុខភាពពិភពលោក

អនុសញ្ញាគោលនៃអង្គការសុខភាពពិភពលោក

១- ថ្នាំជក់ ការផ្គត់ផ្គង់និងការចែកចាយ ២- ឧស្សាហកម្មថ្នាំជក់ នីតិកម្ម ៣-ការបំពុលនៃផ្សែងថ្នាំជក់ ការបង្ការ និងការត្រួតពិនិត្យ ៤- ការឈប់ប្រើថ្នាំជក់ ៥- សន្ធិសញ្ញា

I. **អង្គការសុខភាពពិភពលោក**

ISBN 92 41591013 (LC/NLM classification: HD 9130.6)

© អង្គការសុខភាពពិភពលោកឆ្នាំ២០០៣ បោះពុម្ពជាថ្មីឡើងវិញ និងផ្តល់ទិន្នន័យថ្មីបំផុតឆ្នាំ២០០៤

រក្សាគ្រប់សិទ្ធិទាំងអស់ ។ ឯកសារបោះពុម្ពផ្សាយដោយអង្គការសុខភាពពិភពលោក អាចទទួលបានអង្គភាពម៉ាកឺធីញនិងការផ្សព្វផ្សាយនៃអង្គការសុខភាពពិភពលោកអាស័យដ្ឋានលេខ ២០ វុក្ខវិថី Appia, 1211 ទីក្រុងហ្សឺណែវ ២៧ ប្រទេសស្វីស ( ទូរស័ព្ទ: + 41 22 791 2476, ទូរសារ: +41 22 791 4857. Email: bookorders@ who.int)

សំណើសុំការអនុញ្ញាតបោះពុម្ពជាថ្មី ឬបកប្រែឯកសារបោះពុម្ពផ្សាយដោយអង្គការសុខភាពពិភពលោក ទោះជាសម្រាប់លក់ ឬសំរាប់ការចែកចាយមិនមែនពាណិជ្ជកម្ម ត្រូវស្នើទៅអង្គភាពបោះពុម្ពផ្សាយនៅអាសយដ្ឋានខាងលើ ( ទូរសារ: +41 22 791 4857. Email: bookorders@who.int) ។

ឈ្មោះដែលប្រើ និងការបង្ហាញសម្ភារៈនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ ពុំមានពាក់ព័ន្ធដល់ការសំដែងនូវមតិរបស់អង្គការសុខភាពពិភពលោក ទាក់ទងដល់ឋានៈច្បាប់របស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ ឬអាជ្ញាធរណាមួយ ឬទាក់ទងដល់ការកំណត់ព្រំដែនឡើយ ។ ខ្សែបន្ទាត់ដែលគូសនៅលើផែនទី គ្រាន់តែបង្ហាញនូវបន្ទាត់ព្រំដែនប្រហាក់ប្រហែល ហើយក៏ប្រហែលជាពុំទាន់មានការព្រមព្រៀងពេញលេញនៅឡើយ ។

ការនិយាយពីក្រុមហ៊ុនណាមួយ ឬផលិតផលរបស់កម្មន្តសាលណាមួយក៏មិនមែនមានន័យថា អង្គការសុខភាពពិភពលោកបានផ្តល់នូវការគាំទ្រ ឬចូលចិត្តជាងផលិតផលដូចគ្នា ដែលពុំបានលើកយកមកនិយាយនោះទេ ។ លើកលែងតែមានការភ័ន្តច្រឡំ ឬភ្លេចក្តាំងអក្សរដើមនៃម្ចាស់ផលិតផល ត្រូវបានសរសេរជាអក្សរធំ ។

អង្គការសុខភាពពិភពលោក ពុំធានាថា ព័ត៌មានដែលមាននៅក្នុងឯកសារបោះពុម្ពផ្សាយនេះគ្រប់គ្រាន់ ឬត្រូវតែតខ្វះនោះទេ ហើយក៏ពុំត្រូវជាប់បន្ទុកទទួលខុសត្រូវដល់ការខូចខាតដែលបណ្តាលមកពីលទ្ធផលនៃការប្រើប្រាស់វាដែរ ។

បោះពុម្ពនៅអង្គការសុខភាពពិភពលោក ទីក្រុងហ្សឺណែវ ។

# អនុសញ្ញារបស់អង្គការសុខភាពពិភពលោក
# ស្តីពីការត្រួតពិនិត្យថ្នាំជក់ (ក.អ.ត.ថ)

**មាតិកា**


**បុព្វកថា** ---------------------------------------- ៤

**អារម្ភកថា** ---------------------------------------- ៦

**ផ្នែកទី ១ : សេចក្តីផ្តើម** ---------------------------------------- ៨

មាត្រា ១ : ការប្រើពាក្យ ---------------------------------------- ៨

មាត្រា ២ : ទំនាក់ទំនងរវាងអនុសញ្ញានេះនិងកិច្ចព្រមព្រៀង និងលិខិតតូបករណ៍គតិយុត្តផ្សេងទៀត ------------ ៩

**ផ្នែកទី ២ : គោលដៅ គោលការណ៍ណែនាំ និងកាតព្វកិច្ចទូទៅ** ---------------------------------------- ៩

មាត្រា ៣ : គោលដៅ ---------------------------------------- ៩

មាត្រា ៤ : គោលការណ៍ណែនាំ ---------------------------------------- ១០

មាត្រា ៥ : កាតព្វកិច្ចទូទៅ ---------------------------------------- ១១

**ផ្នែកទី ៣ : វិធានការទាក់ទងដល់ការបន្ថយតម្រូវការថ្នាំជក់** ---------------------------------------- ១១

មាត្រា ៦ : តម្លៃ និងវិធានការពន្ធដារ ដើម្បីបន្ថយតម្រូវការថ្នាំជក់ ---------------------------------------- ១២

មាត្រា ៧ : វិធានការមិនទាក់ទងនឹងតម្លៃដើម្បីបន្ថយតម្រូវការថ្នាំជក់ ---------------------------------------- ១២

មាត្រា ៨ : ការការពារប្រឆាំងនឹងការរងផ្សែងថ្នាំជក់ ---------------------------------------- ១២

មាត្រា ៩ : បទបញ្ជាចំពោះវត្ថុធាតុដែលមាននៅក្នុងផលិតផលថ្នាំជក់ ---------------------------------------- ១៣

មាត្រា ១០ : បទបញ្ជាចំពោះការប្រាប់ឱ្យដឹងអំពីផលិតផលថ្នាំជក់ ---------------------------------------- ១៣

មាត្រា ១១ : ការវេចខ្ចប់ និងការបិទផ្លាកលើផលិតផលថ្នាំជក់ ---------------------------------------- ១៣

មាត្រា ១២ : ការអប់រំ ការផ្តល់ព័ត៌មាន ការបណ្តុះបណ្តាល និងការយល់ដឹងរបស់សាធារណជន-------------- ១៤

មាត្រា ១៣ : ការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយលក់ និងការឧបត្ថម្ភកម្មវិធីសំរាប់ថ្នាំជក់ ---------------- ១៥

មាត្រា ១៤ : វិធានការបន្ថយការញៀនបារី និងការឈប់ជក់ ---------------------------------------- ១៧

**ផ្នែកទី ៤ : វិធានការទាក់ទងដល់ការបន្ថយការផ្តល់ថ្នាំជក់** ---------------------------------------- ១៧

មាត្រា ១៥ : ការធ្វើជំនួញខុសច្បាប់លើផលិតផលថ្នាំជក់ ---------------------------------------- ១៧

មាត្រា ១៦ : ការលក់ទៅឱ្យ ឬដោយអនីតិជន ---------------------------------------- ១៩

មាត្រា ១៧ : ការផ្តល់ការឧបត្ថម្ភចំពោះសកម្មភាពជំនួសដែលអាចធ្វើអោយរស់បាន --------------------- ២០

**ផ្នែកទី ៥ : ការការពារបរិស្ថាន** ---------------------------------------- ២០

មាត្រា ១៨ : ការការពារបរិស្ថាន និងសុខភាពប្រជាជន ---------------------------------------- ២០